00250981

C26/5/4

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ព (អ.ប.ជ១៥) |
| **ដាក់ជូន:** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទនៃឯកសារ:** | ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន:** | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម:** | ភាសាអង់គ្លេស |
| **ប្រភេទឯកសារ:** | **សាធារណៈ** |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 12 / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសំណើជាយថាហេតុ និង បន្ទាន់បំផុតដើម្បីស្នើសុំឱ្យមាន ការដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨

---

**ដាក់ជូនដោយ:**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Vincent de WILDE d' ESTMAEL

**ជូន:**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម ន៏យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**មេធាវីការពារក្តី ខៀវ សំផន:**

លោក ស ស៊ូវ៉ាន

លោក Jacques VERGÈS

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

## ១.សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងសំណើជាយថាហេតុនិងបន្ទាន់បំផុតដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាព[1] (ហៅកាត់ថា "សំណើបន្ទាន់") ដាក់តម្កល់ជូនថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៨ ដោយមេធាវី ការពារក្តី ខៀវ សំផន ("ជនត្រូវចោទ") នៅចំពោះមុខអង្គបុរេជំនុំជម្រះ ("អ.ប.ជ") និង/ឬ ប្រធាន ។ សំណើរបស់មេធាវីការពារក្តីមិនត្រូវបានដាក់ជូនដោយអនុលោមតាម វិធានណាមួយនៃវិធានផ្ទៃក្នុង អ.វ.ត.ក ទេ ប៉ុន្តែដោយអនុលោមតាមមាត្រា២៨៣នៃក្រមនីតិព្រហ្មទណ្ឌ។ មេធាវីការពារក្តី ស្នើទៅប្រធានអង្គបុរេជំនុំជម្រះសុំចេញបញ្ជាឱ្យមានការដោះលែង ខៀវ សំផន បណ្តោះអាសន្ន ជាវិធានការ បង្ការនិង ទប់ស្កាត់ដោយរង់ចាំសេចក្តីសម្រេចលើអង្គសេចក្តីទៅលើបណ្តឹងឧទ្ធរណ៍ ដែលដាក់ជូនដោយ មេធាវីការពារក្តី ។ អនុលោមតាម "សេចក្តីបង្គាប់ដល់ភាគីពាក់ព័ន្ធ" ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៨[2] ចម្លើយតបនេះគឺដាក់ជូននៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០៨ ហេតុដូច្នេះវាអាចទទួលយកបាន ។

២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើបន្ទាន់របស់មេធាវីការពារក្តីគួរត្រូវបដិសេធចោលទាំងស្រុងដោយហេតុផលដូចខាងក្រោម៖

(ក) វិធានផ្ទៃក្នុងអ.វ.ត.ក ដែលមានអនុភាពអនុវត្តលើក្រមនីតិវិធីព្រហ្មទណ្ឌនោះ ពុំអនុញ្ញាតឱ្យមានការស្នើសុំដូច្នេះចំពោះមុខ អ.ប.ជ ឬប្រធាន អ.ប.ជ ឡើយ ហេតុដូច្នេះការស្នើសុំជាបន្ទាន់នោះពុំអាចទទួលយកបានឡើយ ។

---

[1] *ករណី ខៀវ សំផន*, ការដាក់ពាក្យបន្ថែមជាបន្ទាន់ស្នើសុំការដោះលែង ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៨, C26/5/2, ERN00250603-07 (ភាសាអង់គ្លេស), 00249810-14 (ភាសាបារាំង) និង 00249815-20 (ភាសាខ្មែរ) ។

[2] ករណី ខៀវ សំផន, សេចក្តីបង្គាប់ដល់ភាគីពាក់ព័ន្ធនឹងសំណើជាយថាហេតុនិងបន្ទាន់បង្អស់របស់លោក ខៀវ សំផន ដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៨, C26/5/3, ERN00250389-90(ភាសាអង់គ្លេស) និង 00250391-92 (ភាសាខ្មែរ) ។

(ខ) បើមិនដូច្នោះទេ មាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលការស្នើសុំនេះបានផ្អែកលើ គឺ ខាងមេធាវីការពារក្តីបកស្រាយខុស ដោយហេតុថាវាពុំអនុញ្ញាតឱ្យភាគីនានាស្នើសុំឱ្យប្រធានសភាស៊ើបសួរ (និងបើផ្អែកលើទឡ្ហីករណ៍ខ្លាំងជាងនេះ អ.ប.ជ) ទទួលនូវការស្នើសុំបន្ទាន់បែបនេះ ឬក៏ផ្តល់ដល់ប្រធាន អ.ប.ជ នូវអំណាចបញ្ជាឱ្យដោះលែងបណ្តោះអាសន្នយ៉ាងដូច្នេះទេ ។

(គ) ជាងនេះទៅទៀត ការស្នើសុំបន្ទាន់នេះខ្វះនូវមូលហេតុសមស្រប និង ជាការបំពាន ។

## ២. ប្រវត្តិនីតិវិធីដែលពាក់ព័ន្ធ

៣. នៅថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨ មេធាវីការពារក្តីជូនដំណឹងទៅ អ.ប.ជ ថាខ្លួនស្វះស្វែងដកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដែលត្រូវបានផ្តល់ការអនុញ្ញាត ដោយ អ.ប.ជ នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៨[3] ។ ទន្ទឹមគ្នានេះដែរ មេធាវីការពារក្តីបានដាក់ពាក្យសុំដោះលែងឱ្យមានសេរីភាព នៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៨ ហើយត្រូវបានបដិសេធដោយ ចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៨ ។ ការជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ដោយមេធាវីការពារក្តី នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៨[4] ប៉ុន្តែបន្ទាប់មកបណ្តឹងនោះត្រូវបានទម្លាក់ចោល ។ នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៨ មេធាវីការពារក្តីក៏បានដាក់បណ្តឹងឧទ្ធរណ៍មួយ នៅចំពោះមុខ អ.ប.ជ

---

[3] *ករណី ខៀវ សំផន*, សេចក្តីជូនដំណឹងស្តីអំពីការដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨, **C26/I/30**, ERN00228787-93 (ភាសាបារាំង) , 00231936-42 (ភាសាអង់គ្លេស); *ករណី ខៀវ សំផន* , សេចក្តីសម្រេចរបស់ អ.ប.ជ ទាក់ទងនឹងសេចក្តីជូនដំណឹងស្តីអំពីការដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០៨, **C26/I31**, ERN00231971-74 (ភាសាអង់គ្លេស) ។

[4] *ករណី ខៀវ សំផន*, ពាក្យបណ្តឹងសុំដោះលែង ខៀវ សំផន ឱ្យមានសេរីភាពបណ្តោះអាសន្នដោយមូលហេតុសុខភាព ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៨, **C36**, ERN 00195934-35 (ភាសាអង់គ្លេស), 00195936-37 (ភាសាបារាំង); សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាទៅលើពាក្យបណ្តឹងរបស់មេធាវីសុំដោះលែងខៀវ សំផន ឱ្យមានសេរីភាពបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៨, **C36/II**, ERN 00196966-69 (អង់គ្លេស); ដីកាសម្រេចបដិសេធសំណើសុំឱ្យដោះលែង, ស.ច.ស, ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៨, **C36/III**, ERN 00197169-73 (ភាសាបារាំង) និង 00198508-12 (ភាសាអង់គ្លេស); សៀវភៅចុះបណ្តឹងឧទ្ធរណ៍ និងជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៨, **C36/III/1**, ERN 00198209-12 (ភាសាអង់គ្លេស) ។

ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីទាក់ទងនឹង ការបក ប្រែ[5] ។ សវនាការជាសាធារណៈត្រូវបានធ្វើ ឡើងទាក់ទងនឹងបញ្ហានេះនៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៨ ហើយ សេចក្តីសម្រេចនៅមិនទាន់ប្រកាសនៅឡើយទេ។ ពាក្យបណ្តឹងស្នើសុំដោះលែងឱ្យមាន សេរីភាពបណ្តោះអាសន្នដែលត្រូវបានដាក់ជូន ស.ច.ស ដោយ មេធាវីការពារក្តី នៅថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨ នោះត្រូវបានឆ្លើយតបដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០៨ រួចហើយត្រូវបានបដិសេធដោយ ស.ច.ស តាមរយៈដីកា ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៨[6] ។ នៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៨ មេធាវីការពារក្តីដាក់បណ្តឹងឧទ្ធរណ៍នៅចំពោះ មុខ អ.ប.ជ ប្រឆាំងនឹងដីកាសម្រេចនោះ[7] ។ នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៨មេធាវីការពារក្តីដាក់ បណ្តឹងឧទ្ធរណ៍មួយទៀតប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថេរ វេលានៃការឃុំខ្លួនបណ្តោះ អាសន្ន ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៨[8] ។ នៅថ្ងៃដដែល ពាក្យស្នើជាបន្ទាន់សុំដោះលែងឱ្យ មានសេរីភាពត្រូវបានដាក់ជូនដោយមេធាវីការពារក្តីនៅចំពោះមុខ អ.ប.ជ ។

---

[5] *ករណី ខៀវ សំផន* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែសំណុំរឿងលោក ខៀវ សំផន ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៨, **A190/I/1**, ERN 00212334-52 (ភាសាអង់គ្លេស) និង 00207411-29 (ភាសាបារាំង) ។ បណ្តឹងឧទ្ធរណ៍នេះផ្ទុកសំណើ សុំដោះលែងឱ្យមានសេរីភាពបណ្តោះអាសន្ន; ដីកាសម្រេចរបស់ ស.ច.ស ស្តីពី សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៨, **A190**, ERN 00196923-30 (ភាសាអង់គ្លេស) ។

[6] *ករណី ខៀវ សំផន*, ការស្នើរបស់មេធាវីការពារក្តីសុំដោះលែង ខៀវ សំផន ឱ្យមានសេរីភាពបណ្តោះអាសន្ន ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨, **C40**, ERN 00228906-18 (ភាសាបារាំង), 00233119-30 (ភាសាអង់គ្លេស); ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង ដីកាបញ្ជូនសំណុំរឿង ទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសំណើរបស់ ខៀវ សំផន សុំឲ្យមានការដោះលែងឱ្យមានសេរីភាព ជាបន្ទាន់, **C40/3**, ERN 00234631-45 (ភាសាអង់គ្លេស); ដីការបស់ ស.ច.ស បដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៨, **C40/4**, ERN 00235033-44 (ភាសាបារាំង), 00236261-71 (ភាសាអង់គ្លេស) ។

[7] *ករណី ខៀវ សំផន*, បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់សចស បដិសេធសំណើសុំការដោះលែងឱ្យមាន សេរីភាព ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៨, ២៧ វិច្ឆិកា ឆ្នាំ ២០០៨, **C40/5/1** និង ឧបសម្ព័ន្ធ **C40/5/1**, ERN 00242949-68 និង ឧបសម្ព័ន្ធ ERN 00242995-98 (ភាសាបារាំង)។ រហូតមកដល់ថ្ងៃនេះពុំទាន់មានសេចក្តីបកប្រែនៅឡើយទេ ។

[8] *ករណី ខៀវ សំផន,* បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹង ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៨, **C26/5/1**, ERN 00249732-48 (ភាសាបារាំង) ។ មកដល់ថ្ងៃនេះពុំទាន់មានសេចក្តីបកប្រែនៅឡើយ ទេ ។ ដីកាសម្រេចរបស់ ស.ច.ស ស្តីអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៨, **C26/4**, ERN 00239460-69 (ភាសាបារាំង) ។

## ៣. ទឡ្ហីករណ៍ច្បាប់

៤. ពាក្យស្នើសុំរបស់មេធាវីការពារក្តីមិនត្រូវបានដាក់ដោយអនុលោមទៅតាម វិធានផ្ទៃក្នុងឡើយ ប៉ុន្តែ យោងទៅលើ មាត្រា២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាតែមួយប៉ុណ្ណោះ ដែលមិនអនុវត្តចំពោះ អ.វ.ត.ក ឡើយ ។

៥. អ.ប.ជ ថ្មីៗនេះសម្រេចថា វិធានផ្ទៃក្នុងមានអានុភាពអនុវត្តលើ បទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ នៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៨ អ.ប.ជ ថ្លែងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ជំទាស់នឹងដីកាបដិសេធសុំមោឃភាព ត្រង់កថាខណ្ឌ ១៤ ថា៖

*"វិធានផ្ទៃក្នុង (...)បង្កើតបានជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈ ពិសេសរបស់ អ.វ.ត.ក ហើយត្រូវបានអនុម័ត និង មានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក ។ វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ប៉ុន្តែគោលបំណង របស់ អ.វ.ត.ក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យ អ.វ.ត.ក មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស ។ ដូច្នេះ វិធានផ្ទៃក្នុងជាលិខិតូបករណ៍ចម្បង ដែលយើងគួរនឹងយកមកពិនិត្យមើល ក្នុងការកំណត់ នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងករណីមានភាព ខុសគ្នារវាងនីតិវិធីនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"*[9] ។

---

[9] *ករណី នួន ជា*, សេចក្តីសម្រេចរបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ជំទាស់នឹងដីកាបដិសេធសុំមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៨, D55/1/8, ERN 00219334-49 (ភាសាខ្មែរ) និង 00219322-33 (ភាសាអង់គ្លេស), កថាខណ្ឌ ១៤ ។

គោលការណ៍នេះត្រូវបានបញ្ជាក់ដោយ អ.ប.ជ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនទៅលើពាក្យស្នើសុំរបស់សហមេធាវីភាគីរដ្ឋប្បវេណីទាក់ទងនឹងការធ្វើអំណះអំណាងផ្ទាល់មាត់នៅក្នុងសវនាការថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៨[10] ។

៦. វិធានផ្ទៃក្នុងនៃ អ.វ.ត.ក មិនអនុញ្ញាតឱ្យមេធាវីការពារក្ដីដាក់ជូន អ.ប.ជ ឬ ប្រធានអ.ប.ជ នូវ "សំណើជាយថាហេតុនិងបន្ទាន់បំផុតដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យមានសេរីភាព" ឡើយ។ ទី១ វិធាន ៧៣ នៃវិធានផ្ទៃក្នុង កម្រិតយ៉ាងច្បាស់លាស់នូវយុត្តាធិការបន្ថែមនៃ អ.ប.ជ ចំពោះតែបណ្ដឹងឧទ្ធរណ៍ ដែលប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ស.ច.ស ដូចមានចែងនៅ ក្នុងវិធាន ៧៤ និង ទទួលយកនូវ ពាក្យសុំមោឃភាពកិច្ចស៊ើបសួរដូចដែលមានចែងក្នុង វិធាន៧៦[11] ។ គ្មានពាក្យសុំបន្ថែមសុំឱ្យមានការដោះលែងត្រូវបានអនុញ្ញាតនៅចំពោះមុខ អ.ប.ជ ឡើយក្រោមវិធានផ្ទៃក្នុង ។ ពាក្យស្នើសុំឱ្យមានការដោះលែងនេះគួរតែដាក់ជូន ស.ច.ស តែប៉ុណ្ណោះ ទៅតាមលក្ខខណ្ឌដែលមាន ចែងនៅក្នុងវិធាន ៦៤ ។ ទី២ មេធាវីការពារក្ដីត្រូវបានកំណត់ដោយវិធានផ្ទៃក្នុងមិនឱ្យដាក់ពាក្យស្នើសុំឱ្យដោះលែងឱ្យមានសេរីភាពបែបនេះចំពោះប្រធាន អ.ប.ជ ឡើយ[12] ។ ចំណុចចុងក្រោយគឺថា ប្រធាន អ.ប.ជ គ្មាន

---

[10] *ករណី ខៀវ សំផន,* សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់ អ.ប.ជ ទៅលើសំណើរដោយផ្ទាល់មាត់របស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងការធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៨, A190/I/16, ERN 00244305 (ភាសាអង់គ្លេស) កថាខណ្ឌ ២។

[11] វិធាន ៧៦.២ ចែងថា ភាគីទាំងឡាយ ដែលយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេតដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំធ្វើមោឃភាព។

[12] ពាក្យស្នើសុំបន្ទាន់ មិនមានលក្ខណៈច្បាស់លាស់ត្រង់ចំណុចនេះ ។ ពាក្យស្នើសុំនេះត្រូវបានដាក់ជូននៅចំពោះមុខ អង្គបុរេជំនុំជម្រះ ប៉ុន្តែតាមពិតស្វះស្វែងរកសេចក្ដីសម្រេចមួយតែពី ប្រធានអង្គបុរេជំនុំជម្រះតែប៉ុណ្ណោះ ដោយហេតុថា មេធាវីការពារក្ដីលើកឡើងថាខ្លួនអាចមានអំណាចពិសេសកំណត់ដោយច្បាប់នៅក្នុងកិច្ចការនេះ ។ ពាក្យស្នើសុំនេះគឺផ្អែកលើមាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលទាក់ទងនឹងអំណាចពិសេសរបស់ប្រធាន ប៉ុន្តែក៏និយាយផងដែរនូវមាត្រាផ្សេងទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងសភាស៊ើបសួរទាំងមូល (មាត្រា ២៦១ និង ២៧៨)។ កថាខណ្ឌ ១៣ នៃពាក្យស្នើសុំនេះ នៅក្នុងភាសាដើមបារាំង បន្ថែមលើភាពច្របូកច្របល់នេះទៀត ដោយមេធាវីការពារក្ដីស្នើសុំឱ្យប្រធានអង្គបុរេជំនុំជម្រះចេញបញ្ជាឱ្យដោះលែងឱ្យមានសេរីភាពបណ្ដោះអាសន្ន "ទៅតាមលក្ខខណ្ឌដែលខ្លួនយល់ថាសមស្រប"។ (សេចក្ដីបកប្រែជាភាសាអង់គ្លេសដែលជូនដំណឹងនៅថ្ងៃទី ១២ ខែធ្នូ មិនឆ្លុះបញ្ចាំងចណុចនេះឱ្យបានត្រឹមត្រូវទេ)។ ភាពមិនច្បាស់លាស់នេះឆ្លុះបញ្ចាំងអំពីការដឹងឮរបស់មេធាវីការពារក្ដីថាខ្លួនពុំមានសិទ្ធិដាក់ពាក្យស្នើសុំបែបនេះទៅកាន់ប្រធានអង្គបុរេជំនុំជម្រះឡើយ ។ វិធានផ្ទៃក្នុងចែងថាមេធាវីការពារក្ដីអាចបានត្រឹមតែដាក់សំណើ អំណះអំណាង ឬ បណ្ដឹងទៅ

អំណាចបញ្ជាដោយខ្លួនឯងឱ្យមានការដោះលែងជនត្រូវចោទឱ្យមានសេរីភាពបណ្ដោះអាសន្ន ជាវិធាន បង្ការ និង ទប់ស្កាត់ឡើយ ។ ក្រៅពីតួនាទីដឹកនាំការតតាំងក្ដីក្នុងពេលសវនាការរបស់អង្គបុរេជំនុំជម្រះអំណាចពិសេសរបស់ប្រធានអង្គបុរេជំនុំជម្រះដែលផ្ដល់ឱ្យតាមរយៈវិធានផ្ទៃក្នុងមានតែនៅក្នុងមាត្រា ៥០ (៣) ៧៧(៣)(ក) និង ៧៧ (១៥) ។[13] ហេតុដូច្នេះពាក្យសុំនេះគួរត្រូវបានបដិសេធចោល ព្រោះវាផ្អែកទៅលើមាត្រា២៨៣នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលមិនអាចអនុវត្តបាននៅចំពោះមុខអង្គបុរេជំនុំជម្រះ ។ មេធាវីការពារក្ដីគួរចងចាំថាមធ្យោបាយតែមួយគត់ដែលអាចកែវិធានផ្ទៃក្នុងបានគឺត្រូវធ្វើសំណើសុំធ្វើវិសោធនកម្មទៅកិច្ចប្រជុំពេញអង្គចៅក្រម ហើយក្នុងករណីរបស់ មេធាវីការពារក្ដី សំណើសុំនោះត្រូវធ្វើតាមរយៈអង្គភាពគាំពារការការពារក្ដី។

## *បើមិនដូច្នោះទេ ការបកស្រាយរបស់មេធាវីការពារក្ដីលើមាត្រា២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាមានការភាន់ច្រឡំ*

៧. ដូចដែលបានលើកឡើងខាងលើ វិធានផ្ទៃក្នុងមានអាទិភាពជាងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាចក្រកម្ពុជាទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក.។ មាត្រា២៨៣ដែលបានលើកឡើងនៅ ក្នុងសំណើបន្ទាន់បង្ខំនេះមិនអាចអនុវត្តបានទេ ហើយមាត្រា២៧៨ក៏មិនអាចអនុវត្តបានដែរ។ លើសពីនេះទៅទៀត មាត្រា២៨៣ មិនបានផ្ដល់ឱ្យប្រធាន

---

ស.ច.ស អ.ប.ជ អង្គជំនុំជម្រះ ឬ អង្គជំនុំជម្រះសាលាកំពូលតែប៉ុណ្ណោះ ប៉ុន្តែមិនអាចដាក់ទៅប្រធានអង្គជំនុំជម្រះក្នុងលក្ខណៈជាបុគ្គលដែលមានអំណាចតុលាការបានឡើយ ។ អំណាចវិសាមញ្ញបែបនេះរបស់ប្រធាន អ.ប.ជ ប្រសិនបើមាន គឺអាចប៉ះពាល់ដល់តុល្យការរវាងចៅក្រមជាតិនិងចៅក្រមអន្តរជាតិនៅ អ.ប.ជ ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និង ច្បាប់ស្ដីពីការបង្កើតឱ្យមាន អ.វ.ត.ក ។

[13] វិធាន៥០(៣) ពាក់ព័ន្ធនឹងអំណាចរបស់ប្រធានអង្គបុរេជំនុំជម្រះក្នុងការផ្ដល់សិទ្ធិអំណាចឱ្យធ្វើការឆែកឆេរ បើទោះបីម្ចាស់ឬអ្នកកាន់កាប់មិនយល់ព្រម ឬមិនមានវត្តមាននៅទីនោះក្ដី។ វិធាន៧៧(៣)(ក)ចែងថា នៅពេលដែលអង្គបុរេជំនុំជម្រះទទួលបានពាក្យបណ្ដឹង ប្រធានត្រូវធ្វើការផ្ទៀងផ្ទាត់ថាសំណុំរឿងនោះមានភាពពេញលេញ និងត្រូវកំណត់កាលបរិច្ឆេទសវនាការ។ វិធាន៧៧(១៥)ទាក់ទងនឹងអំណាចរបស់ប្រធានអង្គបុរេជំនុំជម្រះក្នុងការផ្អាក តាមសំណើរបស់សហព្រះរាជអាជ្ញា ចំពោះការសម្រេចដោះលែងជនត្រូវចោទរបស់សហចៅក្រមស៊ើបអង្កេត ឬការចេញដីកាបដិសេធពាក់ព័ន្ធនឹងជនត្រូវចោទនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ សិទ្ធិអំណាចនេះគឺផ្ទុយគ្នាស្រឡះពីសិទ្ធិក្នុងការចេញដីកាបង្គាប់ឱ្យដោះលែងដែលមេធាវីការពារក្ដីខិតខំស្វះស្វែងរកឱ្យប្រធាអង្គបុរេជំនុំជម្រះក្នុងពាក្យសុំរបស់ខ្លួន។

C26/5/4



សភាស៊ើបសួរនូវអំណាចក្នុងការដោះលែងជនត្រូវចោទដោយឯកឯងឡើយ។ ជាផ្នែកមួយនៃអំណាចរដ្ឋបាលដាច់មុខរបស់ខ្លួនក្នុងឋានៈជាម្ចាស់សមត្ថកិច្ចប្រធានសភាស៊ើបសួរត្រឹមតែអាចធានាការប្រព្រឹត្តិទៅដ៏ល្អនៃមន្ទីរស៊ើបសួររបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។[14]ការបកស្រាយនេះគឺជាការត្រឹមត្រូវដោយហេតុថាមាត្រាក្រោយៗមកទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះពាក់ព័ន្ធនឹងបញ្ហារដ្ឋបាល។[15]

៨. គ្មានអំណាចយុត្តាធិការណាមួយ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែល ផ្តល់អំណាចនោះឱ្យទៅប្រធានសភាស៊ើបសួរ ទោះតាមមាត្រា២៨៣ក្តី និងមាត្រា២៨៤ ដល់ ២៨៦ បន្តបន្ទាប់មកទៀតក្តី។តួនាទីរបស់ប្រធានសភាស៊ើបសួរគឺត្រូវបានកំហិតត្រឹមតែអាចការប្រើប្រាស់សិទ្ធិគ្រប់គ្រងមួយចំនួន លើការប្រព្រឹត្តទៅនៃមន្ទីរស៊ើបសួររបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ភាគីពិតជាគ្មានសិទ្ធិក្នុងការស្នើសុំប្រធានសភាស៊ើបសួរឱ្យចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការដោះលែងជនត្រូវចោទឡើយ។

៩. ដូច្នេះ មេធាវីការពារក្តីបានបកស្រាយខុសលើចរិត និង វិសាលភាពនៃអំណាចរបស់ប្រធានសភាស៊ើបសួរ ដូចដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្រាប់។[16] ប្រសិនបើ

[14] មាត្រា ២៨៣ ចែងថា " ប្រធានសភាស៊ើបសួររ៉ាប់រងលើការប្រព្រឹត្តទៅដ៏ល្អនៃមន្ទីរស៊ើបសួរនៃចៅក្រមស៊ើបសួរ។ ប្រធានសភាស៊ើបសួរផ្ទៀងផ្ទាត់មើលជាអាទិ៍ លក្ខខណ្ឌនៃការអនុវត្តបទប្បញ្ញត្តិស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដីកាតុលាការផ្សេងៗ និងដីកាចាត់ឱ្យស៊ើបសួរជំនួស។ ប្រធានសភាស៊ើបសួររ៉ាប់រងកុំឱ្យនីតិវិធីទាំងឡាយមានការយឺតយ៉ាវដោយមិនសមហេតុផល។ ប្រធានសភាស៊ើបសួរអាចចុះទៅធ្វើអធិការកិច្ចនៅក្នុងមន្ទីរស៊ើបសួរ។

[15] មាត្រា២៨៤ ចែងថា ចៅក្រមស៊ើបអង្កេតគ្រប់រូបត្រូវធ្វើរបាយការណ៍រៀងរាល់ត្រីមាសពីវឌ្ឍនភាពនៃការងារ ដែលសម្រេចបានពីកិច្ចស៊ើបសួរចុងក្រោយដែលបានបំពេញ។ មាត្រា២៨៥ ចែងអំពីអធិការកិច្ចដែលធ្វើឡើងដោយប្រធានមន្ទីរស៊ើបសួរដែលត្រូវធ្វើជារបាយការណ៍ផ្ញើទៅប្រធានសាលាឧទ្ធរណ៍។ មាត្រា២៨៦ចែងថា ប្រធានសភាស៊ើបសួរអាចស្នើឱ្យចៅក្រមស៊ើបអង្កេតចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើចៅក្រមស៊ើបអង្កេតនោះខកខានមិនបានចេញសេចក្តីសម្រេចក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យសុំរបស់ជនត្រូវចោទ។ ប្រធានសភាស៊ើបសួរមិនមានសិទ្ធិចេញសេចក្តីសម្រេចណាមួយទាក់ទងនឹងការឃុំខ្លួនដោយខ្លួនឯងនោះទេ។

[16] ការបកស្រាយខុសនេះអាចចេញមកពីលទ្ធភាពមួយ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់បារាំង ដែលប្រធានសភាស៊ើបសួរអាចដឹកនាំសភាស៊ើបសួរដើម្បីសម្រេចលើការពន្យាការឃុំខ្លួនលើជនត្រូវចោទ ដែលស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន (មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ) មេធាវីមិនអាចធ្វើជាមិនដឹងថា តាំងពីឆ្នាំ១៩៥៣មក ប្រទេសកម្ពុជាលែងស្ថិតនៅ

មាត្រា២៨៣នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រូវបានគេយល់ឃើញថាអាចអនុវត្តបាននៅចំពោះមុខអង្គបុរេជំនុំជម្រះ យើងខ្ញុំសូមលើកឡើងថា មាត្រានេះមិនអនុញ្ញាតនូវអ្វីដែលមេធាវីការពារក្ដីខិតខំស្វែងរកពីប្រធានអង្គបុរេជំនុំជម្រះនោះទេ។

*ពាក្យសុំបន្ទាន់បង្ខំនេះខ្វះមូលហេតុជំរុញទឹកចិត្តត្រឹមត្រូវ និងមានចរិតបំពាន*

១០. ពាក្យសុំបន្ទាន់បង្ខំនេះមិនត្រឹមតែខ្វះមូលដ្ឋានច្បាប់ ដែលអាចចាត់ទុកថាជាការបំពានមួយប៉ុណ្ណោះ ទេប៉ុន្តែពាក្យសុំនេះខ្វះទាំងហេតុផលជំរុញទឹកចិត្តសមស្រប ដើម្បីបញ្ជាក់ពីយុត្តិកម្មនៃការដាក់សំណើជាបន្ទាន់នេះ និងការអះអាងថាមានការរំលោភសិទ្ធិជនត្រូវចោទនោះទៀតផង។

១១. គួររំលឹកថាបណ្ដឹងឧទ្ធរណ៍ទាំងឡាយរបស់ជនត្រូវចោទមិនមានអនុភាពផ្អាកនោះទេ ហើយវិធានផ្ទៃក្នុង ក៏មិនមានចែងពីលទ្ធភាពណាមួយ ក្នុងការទទួលបានអត្ថប្រយោជន៍ពីវិធានការបង្ការ និងទប់ស្កាត់ មុនការចេញសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះដែរ។ នៅក្នុងករណីណាក៏ដោយនៅក្នុងសេចក្ដី សម្រេចរបស់អង្គបុរេជំនុំជម្រះនាពេលអនាគត ទោះសេចក្ដីសម្រេចនោះពាក់ព័ន្ធនឹងសិទ្ធិស្ដីពីការបកប្រែភាសាក្ដី ឬបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាបដិសេធសំណើសុំដោះលែងបន្ទាន់និងដីកាពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នរយៈពេលមួយឆ្នាំទៀតក្ដីប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញសិទ្ធិរបស់ជនត្រូវចោទត្រូវបានរំលោភបំពានដោយប្រការណាមួយនោះ សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តជាបន្ទាន់នូវសេចក្ដីសម្រេចណាមួយដើម្បីដោះលែងជននោះដែលការធ្វើបែបនេះអាចចាត់ទុកថាជាដំណោះស្រាយមួយដែលសមស្របសម្រាប់ជនត្រូវចោទ ។ ទន្ទឹមនឹងនេះដែរ ការអះអាងថាមានការរំលោភសិទ្ធិរបស់ជនត្រូវចោទដែលតែងបានលើកឡើងម្ដងហើយម្ដងទៀត នៅក្នុងគ្រប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីតាំងពីខែមេសាឆ្នាំ២០០៨មកនោះនៅតែមានភាពមិនច្បាស់លាស់និងនៅតែ

---

ក្រោមនឹមអាណានិគមនិយមបារាំងទៀតហើយ ហើយច្បាប់ព្រហ្មទណ្ឌបារាំងក៏មិនអាចអនុវត្តបានដែរទាំងនៅកម្ពុជា និង នៅចំពោះមុខ អ.វ.ត.ក.។

ជាការសន្មតសុទ្ធសាធ។ សហចៅក្រមស៊ើបអង្កេតបានច្រានចោលទឡ្ហីករណ៍ដែលលើកឡើងដោយខាងមេធាវីការពារក្តីជាបន្តបន្ទាប់ ហើយបានយល់ឃើញផ្ទុយមកវិញ ក្នុងដីកាបង្គាប់របស់ខ្លួនចុះថ្ងៃទី២៨ ខែតុលា និងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ថា ការដោះលែងជនត្រូវចោទនឹងបង្កនូវហានិភ័យ និងការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរដល់ជនរងគ្រោះ ព្រមទាំងការថែរក្សាវត្ថុតាង។ ការដោះលែងក៏នឹងបង្កហានិភ័យចំពោះសុវត្ថិភាព និង សន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ និងអាចបង្កការ ប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ។សេចក្តីសម្រេចទាំងនេះស្ថិតនៅជាធរមានតាមវិធានផ្ទៃក្នុងរហូតទល់តែត្រូវបានពិនិត្យឡើងវិញដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូបទៅលើបណ្តឹងឧទ្ធរណ៍។ ការពិនិត្យលើមូលហេតុនៃបណ្តឹងឧទ្ធរណ៍ទាំងនោះដោយប្រធានអង្គបុរេជំនុំជម្រះតែឯកឯងមុនចៅក្រមទាំងប្រាំរូបនោះ នឹងជាការបង្ខំឲ្យគាត់ធ្វើបុរេវិនិច្ឆ័យ។

១២. ជាក់ស្តែង ការកើនឡើងនៃការដាក់ពាក្យសុំឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំបណ្តោះអាសន្នទៅសហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះជាបន្តបន្ទាប់ថ្មីៗនេះ បង្ហាញឱ្យឃើញយ៉ាងច្បាស់ពីចេតនា មិនចង់គោរពតាមលក្ខខណ្ឌតម្រូវនៃវិធាន៦៤(២) និង ៦៤(៣)។ ពាក្យសុំដោះលែងបច្ចុប្បន្ននេះគឺជា ពាក្យសុំលើកទីបួនហើយក្នុងរយៈពេលតិចជាងប្រាំមួយខែចុងក្រោយនេះ ពោលគឺជាស្ថានភាពមួយដែលរំលោភទៅលើវិធាន៦៤(៣) និង អាចចាត់ទុកថាជាការបំពាននីតិវិធីច្បាប់។

## ៤. សេចក្តីសន្និដ្ឋាន

១៣. ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើឱ្យអង្គបុរេជំនុំជម្រះ **បដិសេធចោល** ទាំងស្រុង

00250991

C26/5/4

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ព (អបជ១៥)

នូវពាក្យសុំបន្ទាន់បង្គំរបស់មេធាវីការពារក្តីសុំការដោះលែងនេះ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោក យ៉េត ចរិយា** | **លោក** Robert PETIT |
| **សហព្រះរាជអាជ្ញារង** | **សហព្រះរាជអាជ្ញា** |